**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**
**រដ្ឋបាលជលផល**

លេខ: ៦៧៥០............ជផ

# សេចក្តីជូនដំណឹង
## ស្តីពី
## រដូវបើកនេសាទឆ្នាំ២០១៩-២០២០

**យោង**៖ព្រះរាជក្រមលេខ នស/រកម/០៥០៦/០១១ ចុះថ្ងៃទី២១ ខែឧសភា ឆ្នាំ២០០៦ ស្តីពីការប្រកាសឱ្យប្រើច្បាប់ស្តីពីជលផល

រដ្ឋបាលជលផល នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ សូមជូនដំណឹងដល់សាធារណៈជន និងអ្នកនេសាទទាំងអស់ឱ្យបានជ្រាបថា រដូវបើកនេសាទសម្រាប់ឆ្នាំ២០១៩-២០២០ ត្រូវបានកំណត់ដូចខាងក្រោម៖

-ចាប់ពីថ្ងៃទី០១ ខែតុលា ដល់ថ្ងៃទី៣១ ខែឧសភា ចំពោះដែននេសាទទឹកសាបដែលស្ថិតនៅខាងជើងខ្សែស្របទន្លេចតុមុខ ដែលមានខេត្តទាំងអស់ជុំវិញបឹងទន្លេសាប និងបណ្តាខេត្ត កំពង់ចាម ត្បូងឃ្មុំ ក្រចេះ រតនគិរី មណ្ឌលគិរី ព្រះវិហារ ប៉ៃលិន ឧត្តរមានជ័យ និងមួយផ្នែកក្នុងភូមិសាស្ត្ររាជធានីភ្នំពេញ ខេត្តកណ្តាល ដែលនៅប៉ែកខាងជើងទន្លេចតុមុខ។ ដោយឡែក ខេត្តស្ទឹងត្រែង ចាប់ពីថ្ងៃទី០១ ខែតុលា រហូតដល់ថ្ងៃទី០១ ខែឧសភា។

-ចាប់ពីថ្ងៃទី០១ ខែវិច្ឆិកា ដល់ថ្ងៃទី៣០ ខែមិថុនា ចំពោះដែននេសាទទឹកសាបដែលស្ថិតនៅខាងត្បូងខ្សែស្របទន្លេចតុមុខ រួមមាន៖ ខេត្តព្រៃវែង តាកែវ កំពង់ស្ពឺ ស្វាយរៀង និងមួយផ្នែកក្នុងភូមិសាស្ត្ររាជធានីភ្នំពេញ ខេត្តកណ្តាល ដែលនៅប៉ែកខាងត្បូងទន្លេចតុមុខ។

នៅក្នុងរយៈពេលបើកនេសាទនេះ ប្រជាពលរដ្ឋអាចធ្វើអាជីវកម្មនេសាទដោយឧបករណ៍នេសាទជាលក្ខណៈគ្រួសារ ដែលអនុញ្ញាតនៅក្នុងដែននេសាទទឹកសាប។ ក្រៅពីនេះ ការធ្វើនេសាទត្រូវ៖

+មានលិខិតអនុញ្ញាតឱ្យធ្វើអាជីវកម្មនេសាទ

+មានកាតព្វកិច្ចបង់ពន្ធ និងថ្លៃឈ្នួលនេសាទជូនរដ្ឋ

+គោរពតាមបទបញ្ជាដែលមានចែងក្នុងលិខិតអនុញ្ញាតឱ្យធ្វើនេសាទ។

ចំពោះអ្នកនេសាទដែលមានបំណងធ្វើនេសាទដោយប្រើប្រាស់ឧបករណ៍-ម៉ាញ់។នៅដងទន្លេមេគង្គនិងដងទន្លេសាបក្នុងទីតាំងដែលរាជរដ្ឋាភិបាលបានអនុញ្ញាត ត្រូវអញ្ជើញមកទំនាក់ទំនងចុះឈ្មោះសុំលិខិតអនុញ្ញាតឱ្យធ្វើនេសាទនៅតាមខណ្ឌរដ្ឋបាលជលផល នៃមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទពាក់ព័ន្ធ ដើម្បីបានប្រកបមុខរបរនេសាទ និងទទួលការណែនាំពីសមត្ថកិច្ចជំនាញជលផលអំពីបច្ចេកទេស និងបទបញ្ជានានា ដែលពាក់ព័ន្ធដល់ការធ្វើនេសាទ ដើម្បីធានានូវនិរន្តរភាពនៃធនធានជលផល។

ទទួលបានសេចក្តីជូនដំណឹងនេះ សូមសាធារណៈជនជ្រាបជាព័ត៌មាន។

ថ្ងៃ[illegible]១៣រោច ខែភទ្របទ ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣

រាជធានីភ្នំពេញ ថ្ងៃទី ២៦ ខែកញ្ញា ឆ្នាំ២០១៩

**ប្រតិភូរាជរដ្ឋាភិបាលកម្ពុជា ទទួលបន្ទុកជា**
**ប្រធានរដ្ឋបាលជលផល**

**អេង ជាសាន**

**ចម្លងជូន៖**
-ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
  -ដើម្បីជូនជ្រាបជាព័ត៌មាន-
-គ្រប់រដ្ឋបាលរាជធានី-ខេត្ត
  -ដើម្បីជួយជំរុញការអនុវត្តឱ្យមានប្រសិទ្ធភាព-
-គ្រប់មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរាជធានី-ខេត្ត
-គ្រប់អង្គភាពក្រោមឱវាទរដ្ឋបាលជលផល
  -ដើម្បីតាមដានការបង្ក្រាបបទល្មើសឱ្យបានតឹងរឹង និងមានប្រសិទ្ធភាពបំផុត-
-ស្ថានីយវិទ្យុនិងទូរទស្សន៍
  -ដើម្បីជួយធ្វើការផ្សព្វផ្សាយឱ្យបានទូលំទូលាយ-
-ឯកសារ កាលប្បវត្តិ

អាសយដ្ឋាន៖អាគារលេខ១៨៦ មហាវិថីព្រះនរោត្តម សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ កម្ពុជា ប្រអប់សំបុត្រលេខ៥៨២ ☏/Fax (855) 23 215 470 www.fia.gov.kh
Address #186 Preah Norodom Blvd., Sangkat Tonle Bassac, Khan Chamcar Mon, Phnom Penh capital, Cambodia. P.O Box 582. ☏/Fax (855) 23 215 470 www.fia.gov.kh